00354926

D164/3/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ) ២៥

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរបស់មេធាវីការពារក្តី ស្នើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាង ដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD)**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / JUL / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

<u>ផ្ញើជូន</u>៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

D164/3/1

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ )

អនុលោមទៅតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") លោក **អៀង សារី** តាមរយៈមេធាវីការពារក្តីរបស់ខ្លួន សូមដាក់បណ្តឹងឧទ្ធរណ៍នេះ ប្រឆាំងទៅលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរួមរបស់មេធាវីការពារក្តីដែលស្នើសុំបំពេញកិច្ចស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ("MSD" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០០៩ ("**ដីកា**")។ តាមរយៈដីកាសម្រេចនេះ កសចស បង្ហាញឲ្យឃើញពីវិធីសាស្ត្រមិនត្រឹមត្រូវទាំងស្រុង ចំពោះករណីយកិច្ចរបស់ខ្លួនក្នុងការស៊ើបសួរដោយអនាគតិ ដែល ប្រសិនបើអង្គបុរេជំនុំជម្រះមិនកែតម្រូវទេ នោះនឹងបណ្តាលឲ្យកិច្ចស៊ើបសួរមិនមានលក្ខណៈគ្រប់គ្រាន់ លំអៀង និងអយុត្តិធម៌យ៉ាងជាក់ស្តែង។ បន្ទាប់ពីបានពិនិត្យលើបណ្តឹងឧទ្ធរណ៍រួមដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកា[1] និង សម្រាប់មូលហេតុសេដ្ឋកិច្ចរបស់តុលាការ មេធាវីការពារក្តីសូមចូលរួម និង ដាក់បញ្ចូលនូវអំណះអំណាងខាងអង្គហេតុ និង អង្គច្បាប់ពាក់ព័ន្ធទាំងអស់ ដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍រួមនេះ ហើយសូមធ្វើសេចក្តីសន្និដ្ឋានបន្ថែមដោយផ្អែកលើមូលហេតុពីរ ៖ (ក)"គោលការណ៍នៃភាពគ្រប់គ្រាន់ដែលត្រូវបានស្នើ" ដែលត្រូវបានសំអាងដោយ កសចស[2] និង (ខ) ការសំអាងរបស់ កសចស លើសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជម្រះក្តីដោយគ្មានបង្អង់ ជាមធ្យោបាយនៃការបដិសេធសិទ្ធិរបស់គាត់ក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌[3]។

## I. ច្បាប់

1. មេធាវីការពារក្តីសូមដាក់បញ្ចូលអត្ថបទច្បាប់ដែលយោងនៅក្នុងបណ្តឹងឧទ្ធរណ៍រួម[4]។

## II. សង្ខេបនៃអង្គហេតុ

2. មេធាវីការពារក្តីនឹងបង្ហាញថា ៖

---

[1] បណ្តឹងឧទ្ធរណ៍រដោយ នួន ជា និង អៀង ធីរិទ្ធ ដែលមានចំណងជើងថា "បណ្តឹងឧទ្ធរណ៍រួមរបស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើសុំបំពេញកិច្ចស៊ើបចូរវដ្បើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុង SMD ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩ ("បណ្តឹងឧទ្ធរណ៍")។

[2] ដូចខាងលើ កថាខណ្ឌ ១៨ ដល់ ២១ ។

[3] ដូចខាងលើ កថាខណ្ឌ ២៩ ដល់ ៣៤ ។

[4] ដូចខាងលើ កថាខណ្ឌ ១០ ដល់ ១៧ ។

ក. ពុំមាន "គោលការណ៍នៃភាពគ្រប់គ្រាន់" នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និង

ខ. កសចស ត្រូវបានហាមឃាត់ជាដាច់ខាតក្នុងការយកមកសំអាងលើសិទ្ធិមួយរបស់លោក អៀង សារី គឺសិទ្ធិមនុស្ស/សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ ដើម្បីបដិសេធគាត់ពីការអនុវត្តសិទ្ធិដទៃឲ្យបានពេញលេញ និង ទាំងស្រុង។

## III. ឧទ្ធិករណ៍

### ក. ពុំមានគោលការណ៍នៃភាពគ្រប់គ្រាន់របស់ភស្តុតាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡើយ

3. ដីកាចែងថា "គោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាងមានប្រៀបលើ ៖ កិច្ចស៊ើបសួរអាចបញ្ចប់បាន <u>នៅពេលដែលចៅក្រមស៊ើបអង្កេតសំដែងការជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនត្រូវចោទ"</u>[5]។

4. តាមពិតបើយោងទៅតាមវិធាន ៦៧(៣)(គ) កសចស អាចចេញដីកាដំណោះស្រាយដោយលើកលែងការចោទប្រកាន់ ប្រសិនបើ "ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ"។ ផ្ទុយទៅវិញ កសស អាចចេញដីកាដំណោះស្រាយប្រឆាំងនឹងជនត្រូវចោទ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់។ សន្មតថា នេះគឺជាវិធានដែល កសចស អនុវត្តចំពោះគោលការណ៍នៃភាពគ្រប់គ្រាន់ដែលត្រូវបានសន្មត បើទោះបីជា កសចស ពុំបានផ្តល់ការសំអាងក៏ដោយ។

5. ការតម្រូវថាជនត្រូវចោទអាចបញ្ជូនទៅជំនុំជម្រះ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកទៅលើគាត់ គឺខុសគ្នាទាំងស្រុងពីការអនុញ្ញាតឲ្យ កសចស បញ្ចប់កិច្ចស៊ើបសួរភ្លាមៗនៅពេលដែលភស្តុតាងទាំងនេះត្រូវបានប្រមូល ដូចដែល កសចស បានអះអាង។ ការអនុញ្ញាតឲ្យ កសចស បញ្ចប់កិច្ចស៊ើបសួរភ្លាមៗនៅពេលដែលខ្លួនជឿជាក់ថា ប្រមូលបានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកទៅលើជនត្រូវចោទ "នេះផ្ទុយនឹងប្រព័ន្ធច្បាប់មួយទាំងស្រុង ខណៈដែលចៅក្រមស៊ើបអង្កេត

[5] ដីកា កថាខណ្ឌ ៦ បញ្ជាក់បន្ថែម ។

មានអំណាចផ្តាច់មុខលើការស៊ើបសួរ[6] និងត្រូវដឹកនាំការស៊ើបសួរដោយអនាគតិ ដើម្បីស្វែងរកយុត្តិភាពស្មើគ្នាទាំងភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុក[7]។

6. កសចស ហាមឃាត់ភាគីមិនឱ្យធ្វើការស៊ើបសួរដោយខ្លួនឯង ដូច្នេះហើយភាគីនិមួយៗពឹងផ្អែកទាំងស្រុងទៅលើការស៊ើបសួររបស់ កសចស ជំនួសឱ្យពួកគេ[8]។ ការបញ្ចប់ការស៊ើបសួរភ្លាមៗនៅពេលដែលសហចៅក្រមស៊ើបអង្កេតជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកទៅលើជនជាប់ចោទ នោះនឹងបដិសេធជនត្រូវចោទពីការស្វែងរកនូវភស្តុតាងដោះបន្ទុកយ៉ាងល្អិតល្អន់ដែលគាត់មានសិទ្ធិទទួលបានភស្តុតាងបែបនេះ។ តាមពិត ប្រសិនបើគោលការណ៍នៃភាពគ្រប់គ្រាន់ នេះមានប្រសិទ្ធិភាពអនុវត្ត កសចស អាចគ្រាន់បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរដែលស្នើឡើងដោយមេធាវីការពារក្តី ដោយផ្អែកលើគោលការណ៍ដែលថា ខ្លួនបានស្វែងរកភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកទៅលើជនត្រូវចោទ ហើយអាស្រ័យហេតុនេះ កសចស អាចបញ្ចប់កិច្ចស៊ើបសួរ។

7. បន្ថែមពីលើនេះ ខណៈដែលការស៊ើបសួររបស់ កសចស អាចត្រូវបានធ្វើឡើយដោយអនុលោមតាមវិធាន ៥៥(១) តាមរយៈការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរដោយ កសព អនុលោមតាមវិធាន ៥៣(១) ហើយការស៊ើបសួរត្រូវបញ្ចប់ភ្លាមៗនៅពេលមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកទៅលើជនត្រូវចោទ គឺពិតជាធ្វើឱ្យប៉ះពាល់ដល់មេធាវីការពារ។ កសព គ្រាន់តែបានដាក់ភស្តុតាង ដើម្បីគាំទ្រដល់ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះដែលជាវិធីសាស្ត្រមួយ ហាក់ដូចជាការអនុវត្តលើការដាក់ឯកសាររបស់ខ្លួន ដោយមិនបាន

---

[6] មាត្រា ៥(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("**កិច្ចព្រមព្រៀង**") អនុម័តនៅថ្ងៃទី៦ មិថុនា ២០០៣។

[7] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ។

[8] ហេតុដូច្នេះ សមត្ថភាពរបស់ភាគីក្នុងការចូលអន្តរាគមន៍ត្រូវកម្រិតត្រឹមតែការសាកសួរបឋម ដែលចាំបាច់បំផុតសម្រាប់ការអនុវត្តសិទ្ធិរបស់ពួកគេឱ្យមានប្រសិទ្ធិភាពចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរ" ករណីរបស់ នួន ជា សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស អនុស្សារណៈរបស់ កសចស ទៅមេធាវីការពារ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៩ ទំព័រ ២។

ពិចារណាអំពីសីលធម៍ដែលពាក់ព័ន្ធ[9]។ ដើម្បីបញ្ចប់ការស៊ើបសួរឱ្យបានឆាប់ៗ ហើយធ្វេសប្រហែសក្នុងស្វែងរកភស្តុតាងដោះបន្ទុក ដែលអាច "សន្និដ្ឋានពីការគ្មានពិរុទ្ធភាព ឬ សម្រាលពិរុទ្ធភាពរបស់ជនសង្ស័យ ឬ ជនត្រូវចោទ ឬ អាចធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់លើភស្តុតាងដាក់បន្ទុក"[10] មានន័យថាមានតែភស្តុតាងដាក់បន្ទុកទេ ដែលដាក់នៅក្នុងសំណុំរឿង។ ហេតុដូច្នេះ មានតែភស្តុតាងនៅក្នុងមានសំណុំរឿងទេដែលអាចយកមកសំអាងនៅសវនាការ ហើយអាចបង្កើតជាមូលដ្ឋាននៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[11] ដែលការខកខានមិនបានស៊ើបសួរ ឱ្យបានត្រឹមត្រូវដើម្បីស្វែងរកភស្តុតាងនេះក្នុងអំឡុងពេលស៊ើបសួរ នឹងបង្កឱ្យមានការជំនុំជម្រះអយុត្តិធម៌ដោយចៀសមិនរួច ដែលរំលោភ លើវិធាន ២១(១)(ក) យ៉ាងច្បាស់ក្រឡែត។

8. កសចស មានករណីកិច្ចក្រោមវិធានផ្ទៃក្នុងដើម្បីស្វែងរកភស្តុតាងដោះបន្ទុកយ៉ាងសកម្ម និង ដោយយកចិត្តទុកដាក់។ វិធាន ៥៥(៥) ចែងថា កសចស "ត្រូវដឹកនាំការស៊ើបសួរដោយអនាគតិ ទោះបី

[9] សូមមើលករណីរបស់លោក អៀង សារី ករណីលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់លោក អៀង សារី ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌទី៣ ស្នើសុំដាក់ទណ្ឌកម្មទៅលើសហព្រះរាជអាជ្ញាចំពោះការនាំឱ្យតុលាការយល់ខុស ទាក់ទងនឹងច្បាប់ស្តីពីសហកម្មឧក្រិដ្ឋកម្មរួមដែល កសព អះអាងថា "...ការសង្កេតបបន្ថែមផ្ទុះបញ្ចាំងយ៉ាងត្រឹមត្រូវពីយល់ឃើញរបស់ពួកគេទៅលើច្បាប់ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម នៅពេលដាក់សារណារបស់ខ្លួន។ ខណៈគ្មានទឡ្ហីករណ៍ផ្នែកច្បាប់ដែលអាចអះអាង ដើម្បីយោងទៅលើករណីយុត្តិសាស្ត្រដែលអាចរកបានទាំងអស់ទាក់ទងនឹងបញ្ហានេះ, ចំពោះការយល់ឃើញ និង ជឿជាក់របស់សហព្រះរាជអាជ្ញា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានបញ្ចូលការពិនិត្យឡើងវិញនៃករណីយុត្តិសាស្ត្រយ៉ាងទូលំទូលាយ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា.." សូមមើលកថាខណ្ឌទី៥ "ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍មានការសោកស្តាយក្នុងចិត្តដែលថា សហព្រះរាជអាជ្ញាមិនបានដាក់ឯកសារណាមួយ ដែលអាចធ្វើអោយខូចដល់ករណីរបស់សហព្រះរាជអាជ្ញា នោះវាជាការបើកចំហរដល់ដើមបណ្តឹងឧទ្ធរណ៍ ដើម្បីនាំឯកសារនេះជាចំណាប់អារម្មណ៍របស់សហចៅក្រមស៊ើបអង្កេត ដើម្បីជួយពួកគេក្នុងការសម្រេចដោយយុត្តិធម៌លើបញ្ហាអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម"។ ចំនុចនេះបង្ហាញយ៉ាងច្បាស់ថា កសព មានទស្សនៈថា ខ្លួនចាំបាច់ផ្តល់ជូនកសចស (និងតុលាការជាទូទៅ) នូវព័ត៌មានទាក់ទងនឹងអង្គហេតុ និងអង្គច្បាប់ តែប៉ុណ្ណោះ ដែលខ្លួនជឿជាក់ថាមានអំណោយផលដល់ជំហររបស់ខ្លួន បើទោះបីមិនបានឆ្លុះបញ្ចាំងទៅលើព័ត៌មានពាក់ព័ន្ធចាំបាច់ទាំងអស់សម្រាប់ដំណើរការនីតិវិធីត្រឹមត្រូវនិងយុត្តិធម៌ក៏ដោយ។ តាមពិត ការយល់ឃើញរបស់ កសព ចំពោះតួនាទី និង ករណីកិច្ចរបស់ខ្លួន គឺផ្ទុយនឹងប្រព័ន្ធច្បាប់ស៊ីវិល ដែលជាមូលដ្ឋានបង្កើត អវតកនេះ។

[10] សូមមើលវិធាន ៥៣(៤) ដែលចែងអំពីនិយមន័យនៃភស្តុតាងដោះបន្ទុកនេះ។

[11] វិធាន ៨៧(៣)។

ជាភស្តុតាងដែលនឹងរកបានជាភស្តុតាងដាក់បន្ទុក ឬ ភស្តុតាងដោះបន្ទុកក៏ដោយ"[12]។ វាជាការសមហេតុផលថា ពាក្យបញ្ញា "ត្រូវតែ" ត្រូវបានប្រើជំនួសពាក្យ "អាច" ដោយសារតែវាបង្ហាញថាអំណាចឆន្ទានុសិទ្ធិពុំបានមានទេសម្រាប់ កសចស ទាក់ទងនឹងការដឹកនាំការស៊ើបសួរដោយអនាគតិ។ កសចស ត្រូវបានហាមឃាត់ពីការស្វែងរកតែភស្តុតាងដែលគាំទ្រដល់ការចោទប្រកាន់របស់ កសព ច្រើនជាងភស្តុតាងដែលអាចច្រានចោលការចោទប្រកាន់បែបនេះ។ កសចស ត្រូវតែផ្តល់ការយកចិត្តទុកដាក់ឱ្យបានស្មើៗគ្នាចំពោះការប្រមូល និង ការវិភាគទាំងភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុក[13]។

9. ក្នុងការគាំទ្រដល់គោលការណ៍នៃភាពគ្រប់គ្រាន់ដែលបានសន្មត កសចស ប្រកាសបន្ថែមថា "សហចៅក្រមស៊ើបអង្កេតមានអំណាចឆន្ទានុសិទ្ធិ ជ្រើសរើសមធ្យោបាយសម្រាប់ស្វែងរកការពិត"[14]។ កសចស ទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរកការពិត។ ទោះជាយ៉ាងណាក៏ដោយ ដោយមិនគិតថាតើការស៊ើបអង្កេតចប់សព្វគ្រប់ ឬ យ៉ាងណានោះ រួមជាមធ្យោបាយទាំងអស់ដែលឈានទៅរកភស្តុតាងដោះបន្ទុកត្រូវបានប្រើប្រាស់អស់ពីលទ្ធភាព នោះ កសចស តាមរយៈដីកាសម្រេច បានបញ្ជាក់ថា ការបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលមានភស្តុតាងគ្រប់គ្រាន់ គឺជាមធ្យាបាយមួយនៃការស្វែងរកការពិត។ ចំនុចនេះគឺមិនត្រឹមត្រូវនោះទេ។ មានការផ្ទុយគ្នាដែលជាប់មកជាមួយរវាងការស្វែងរកការពិត និង ការបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលភស្តុតាងក្នុងកម្រិតអប្បរមាត្រូវបានទទួល ដើម្បីបញ្ជូនរឿងទៅជំនុំជម្រះ។ ការស្វែងរកការពិតលើអង្គហេតុមួយមានន័យថា ក្រឡេកមើលស្ថានភាពជាក់ស្តែងមួយពីគ្រប់ផ្នែកទាំងអស់ និង ការពិនិត្យពិច័យភស្តុតាងទាំងអស់ ដែលគាំទ្រដល់ផ្នែកនីមួយៗ។ ជាការផ្ទុយស្រឡះ ការបញ្ជូនរឿងទៅជំនុំជម្រះនៅពេលភស្តុតាងគ្រប់គ្រាន់ មិនអាចទាំងអះអាងពីការស្វែងរកការពិតបានផង។

---

[12] បញ្ជាក់បន្ថែម ។

[13] សូមមើលករណីរបស់លោក អៀង សារី ករណីលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៣ របស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ។

[14] អក្សរគ្រង់លេខយោងទី ២ នៃដីកាសម្រេច។

10. ហេតុដូច្នេះ ខុសពីទស្សនៈច្បាប់ស៊ីវិល[15] ការបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលមានភស្តុតាងគ្រប់គ្រាន់ គឺស្រដៀងគ្នាច្រើនទៅនឹងវិធីសាស្ត្ររបស់ព្រះរាជអាជ្ញាអនុវត្តប្រព័ន្ធច្បាប់ កុម្ម៉នឡ។ នៅក្នុងចក្រភពអង់ ព្រះរាជអាជ្ញា (the Crown Prosecution Services) នឹងធ្វើការ ចោទប្រកាន់ជនណាម្នាក់បាន តែក្នុងករណីមាន "ភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តល់ 'សេចក្តីរំពឹងពិតៗ លើការផ្តន្ទាទោស' ចុងចោទម្នាក់ៗ"[16]។ ប៉ុន្តែ នៅក្នុងប្រព័ន្ធច្បាប់កុំម៉នឡ មេធាវីការពារក្តីទទួលខុសត្រូវចំពោះការស៊ើបអង្កេតរបស់ខ្លួនផ្ទាល់ ហើយយ៉ាងហោចណាស់ ក៏អាចធ្វើការតទល់នឹងការចោទប្រកាន់បានដែរ។ ស្រដៀងគ្នានេះដែរ មានករណីបែបនេះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិចំពោះកិច្ច (ICTY/ICTR)[17]។ ដោយការអនុវត្តតាមអ្វីដែលហៅថា "គោលការណ៍នៃភាព

---

[15] អវតក គឺជាប្រព័ន្ធច្បាប់ស៊ី ដូចដែលបានទទួលស្គាល់ដោយ កសចស។ សំណុំរឿងរបស់លោក **អៀង សារី** លេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌទី ១៣។

[16] ផ្នែក ៥.២ ក្រមសម្រាប់ព្រះរាជអាជ្ញា របស់ចក្រភពអង់គ្លេស ២០០៤។

[17] នីតិវិធីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិចំពោះកិច្ច មានលក្ខណៈកូនកាន់ ដែលក្នុងនោះ មួយផ្នែកដឹកនាំដោយគូភាគី ហើយមួយផ្នែកដឹកនាំដោយចៅក្រម។ សូមមើល Patrick L. Robinson ការជំនុំជម្រះក្តីឆាប់រហ័ស និងយុត្តិធម៌ នៅ *the ICTY*, 11 E.J.I.L. 569 (2000); Kai Ambos, *នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ: ប្រព័ន្ធដឹកនាំដោយគូភាគី (Adversarial'), ប្រព័ន្ធដឹកនាំដោយចៅក្រម (Inquisitorial'), ឬប្រព័ន្ធចម្រុះ (Mixed'),* 3 INT'L CRIM. L. R. 1 (2003); Alphons Orie, *ប្រព័ន្ធដឹកនាំដោយព្រះរាជអាជ្ញា ទល់នឹង ប្រព័ន្ធដឹកនាំដោយចៅក្រម នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ* vol 2, ១៤៣៩-១៤៩៥ (ចៅក្រម Antonio Cassese និងអ្នកផ្សេងទៀត eds., Oxford University Press, 2002)។ វាជាដំណើរការជម្រុញដោយគូភាគី។ គូភាគី (អយ្យការ និងមេធាវីការពារ) ពាក់ព័ន្ធនៅក្នុងការប្រមូលភស្តុតាងរបស់ខ្លួន និងការដាក់រឿងក្តីរបស់ខ្លួនផ្ទាល់។ អយ្យការមានឯករាជ្យភាពនៅក្នុងការសម្រេចជ្រើសរើសថាអ្នកណាដែលត្រូវស៊ើបអង្កេត, អ្នកណាដែលត្រូវចោទប្រកាន់, ភស្តុតាងដែលខ្លួនមានបំណងប្រមូល, របៀបដែលខ្លួនប្រមូលភស្តុតាង, សាក្សីដែលខ្លួនមានបំណងសាកសួរ, បទចោទដែលខ្លួនមានបំណងដាក់បញ្ចូលដីកាចោទប្រកាន់ និងភស្តុតាងដែលខ្លួនមានបំណងដាក់ជូនអង្គសវនាការ។ សូមមើល Patricia M. Wald, តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី Comes of Age: *ការសង្កេតការណ៍ទៅលើបញ្ហាប្រចាំថ្ងៃខ្លះៗនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ* (*Some Observations on Day-to-Day Dilemmas of an International Court*), 5 Wash. U. J. L. & POL'Y, 87, 99-101 (2001)។ ដូចគ្នានេះដែរ មេធាវីការពារក្តីមានឯករាជ្យភាពនៅក្នុងការបំពេញកិច្ចស៊ើបសួររបស់ខ្លួន: សាក្សីណាដែលត្រូវស្តាប់ចម្លើយ, ភស្តុតាងអ្វីខ្លះដែលត្រូវប្រមូល, សាក្សី និងភស្តុតាងណាខ្លះដែលត្រូវដាក់ជូនអង្គសវនាការ។ សូមមើល John R.W.D. Jones, *The Gamekeeper-Turned-Poacher's Tale*, 2 J. INT'L CRIM. JUSTICE 2 (2004)។

គ្រប់គ្រាន់" កសចស កំពុងបំពេញមុខងារដូចគ្នានឹងព្រះរាជអាជ្ញាដែលអនុវត្តប្រព័ន្ធច្បាប់កុម៉្មនទ្បដែរ តែកំពុងបំពេញមុខងារនេះជាមួយនឹងអំណាចនៃចៅក្រមស៊ើបអង្កេតប្រទេសបារាំង។ ចំនុចត្រង់នេះធ្វើឱ្យលោក អៀង សារី ប្រឈមមុខនឹងផលអាក្រក់ទាំងពីរប្រព័ន្ធ ច្បាប់កុម៉្មង់ទ្បូ និងប្រព័ន្ធច្បាប់ស៊ីវិល ជាមួយនឹងការការពារដែលមាននៅក្នុងប្រព័ន្ធទាំងពីរ។

## ខ. បុគ្គលដែល អវតក បានចោទប្រកាន់ មិនត្រូវបានគេបង្ខំឱ្យជ្រើសរើសរវាងសិទ្ធិជាមូលដ្ឋានរបស់គេនោះទេ

11. កសចស បានសំអាងដដែលៗលើសិទ្ធិមួយរបស់ជនត្រូវចោទ ដើម្បីស្វែងរកការដកហូតពួកគេពីការអនុវត្តសិទ្ធិដទៃទៀត។ កសចស បានស្តីបន្ទោសលោក អៀង សារី ចំពោះការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់ ថាជាការពន្យារការស៊ើបអង្កេត និងកំពុងដកហូតរូបគាត់ពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[18]។ កសចស ក៏បានលើកឡើងថា លោក នួន ជា កំពុងអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដើម្បីដកហូតរូបគាត់ពីសិទ្ធិចូលរួមក្នុងការការពារខ្លួនដោយខ្លួនឯង[19]។ ហេតុដូច្នេះ មិនមានអ្វីគួរឱ្យភ្ញាក់នោះទេថា កសចស បានសំអាងលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយឥតបង្អង់ ដើម្បីបដិសេធសំណើសុំឱ្យ កសចស ស្វែងរកឯកសារនៅក្នុង SMD[20]។ សូមគូសបញ្ជាក់ថា កសចស មិនមានសិទ្ធិ "ជ្រើសរើស"[21] ក្នុងចំណោមសិទ្ធិមនុស្ស/សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ច្បាប់កម្ពុជា និង សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស។ លិខិតគតិយុត្តិទាំងអស់នេះ ត្រូវតែ

---

[18] រឿងក្តីរបស់លោក **អៀង សារី**, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចស្តីពីការបន្ត ថេរវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១០ វិច្ឆិកា ២០០៨ កថាខណ្ឌ ៤១។

[19] រឿងក្តីរបស់លោក នួន ជា, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, លិខិតចុះថ្ងៃទី ១៤ មីនា ២០០៨។ អង្គបុរេជំនុំជម្រះបានច្រានចោលចំនុចនេះ នៅក្នុងសេចក្តីសម្រេចរបស់ កសចស។ សូមមើល សំណុំរឿងរបស់លោក នួន ជា លេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (កសព០៧), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ទាក់ទងនឹងការតែងតាំងអ្នកជំនាញ ចុះថ្ងៃទី ២២ ធ្នូ ២០០៨។

[20] កថាខណ្ឌទី ១០ នៃដីកាសម្រេច ។

[21] សូមមើល កថាខណ្ឌទី ៧ នៃដីកាសម្រេច ដែល កសចស អះអាងថា "...មិនត្រូវធ្វើឡើងតាមរយៈការជ្រើសរើសភស្តុតាងដែលមានស្រាប់..."។ ប្រយោគនេះត្រូវបានប្រើប្រាស់ដោយ កសចស ដែលជាទូទៅ យោងទៅលើ "សកម្មភាពស្វែងរកជម្រើសដែលមានតម្លៃ និងអត្ថប្រយោជន៍ខ្ពស់ ហើយបន្សល់ទុកនូវជម្រើសដែលមានអត្ថប្រយោជន៍សម្រាប់អ្នកផ្សេង"។ សូមមើល ។ *See* http://encarta.msn.com

អនុវត្តឲ្យបានពេញលេញ។ កសចស មិនត្រូវធ្វើយុត្តិកម្មមិនស្មោះត្រង់ច្រំដែលៗ លើការរំលោភសិទ្ធិមួយ ដោយយកលេសថា ជាការការពារសិទ្ធិមួយផ្សេងទៀតនោះទេ។

12. ប៉ុន្តែ ដើម្បីសម្របសម្រួលដល់កិច្ចស៊ើបសួរស្វែងរកសម្ភារៈនៅក្នុង SMD ក្នុងស្ថានការណ៍នេះ ដោយ កសចស លោក អៀង សារី បានចុះហត្ថលេខាលះបង់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជម្រះក្តីដោយគ្មានបង្អង់សម្រាប់រយៈពេលមួយខែ ដើម្បីឲ្យ កសចស ចាត់វិធានការស៊ើបសួរដែលត្រូវបានស្នើសុំ[22]។ មេធាវីការពារស្នើថា អ្នកស៊ើបអង្កេត អ្នកវិភាគ បុគ្គលិកគាំទ្រ និង សហចៅក្រមស៊ើបអង្កេតខ្លួនឯង ត្រូវតែមានលទ្ធភាពបំពេញកិច្ចការដែលត្រូវបានស្នើសុំ ទាក់ទងនឹងសម្ភារៈនេះនៅក្នុងពេលវេលានេះ។ ប្រសិនបើ កសចស នៅតែបង្ខំលោក អៀង សារី ជ្រើសរើសសិទ្ធិមួយ លើសពីសិទ្ធិដទៃទៀត គាត់ត្រូវតែបានអនុញ្ញាតជ្រើសរើសយកសិទ្ធិមួយណាដែលសំខាន់ចំពោះរូបគាត់ នៅក្នុងស្ថានភាពពិសេសបែបនេះ។ ក្នុងករណីបែបនេះ បំណងរបស់ដ៏ធំធេងរបស់គាត់គឺថាដំណើរការនីតិវិធីត្រូវតែយុត្តិធម៌។

## IV. សេចក្តីសន្និដ្ឋាន និង សំណូមពរ

អាស្រ័យដោយហេតុផលដូចបានលើកឡើងនៅទីនេះ មេធាវីការពារក្តីសូមស្នើអង្គបុរេជំនុំជម្រះ សម្រេច ៖

ក. ច្រានចោលចោលដីកាសម្រេចរបស់ កសចស លើសំណើសុំបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម។

ខ. ប្រកាសថា គោលការណ៍នៃភាពគ្រប់គ្រាន់ដែលគាំទ្រដោយ កសចស ពុំមានមាននៅក្នុងប្រព័ន្ធច្បាប់របស់ អវតក ទេ ហើយ កសចស ត្រូវតែផ្តើមការស៊ើបអង្កេតស្វែងរក និងពិចារណាលើភស្តុតាងដោះបន្ទុកទាំងអស់នៅពេលសម្រេចថា តើត្រូវចោទប្រកាន់ជនត្រូវចោទក្រោមវិធាន ៦៧(១) ឬយ៉ាងណា។

គ. បង្គាប់ឲ្យ កសចស ពិនិត្យឡើងវិញនូវឯកសារទាំងអស់ដែលបានដាក់នៅក្នុង SMD។

---

[22] សូមមើលឧបសម្ព័ន្ធ ក។ ប្រសិនបើអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចរបស់ កសចស ដោយផ្អែកលើមូលហេតុនេះក្នុងរយៈពេលមួយខែនេះ នោះនឹងដកចេញពីការជំទាស់តវ៉ាចំពោះដំណើរការនីតិវិធី ដោយមូលហេតុការពន្យារពេលមិនត្រឹមត្រូវ ការលះបង់សិទ្ធិនេះពុំមានអនុភាពលើពេលវេលាដែលបែងចែកដល់ការឃុំខ្លួនបណ្តោះអាសន្ន ស្របតាមវិធាន ៦៣(៧) ឬការផ្តន្ទាទោសក្រោមវិធាន ៩៨(៥)។

00354935

D164/3/1



ឃ. បង្គាប់ឲ្យ កសចស ធ្វើរបាយការណ៍លំអិតគ្រប់គ្រាន់នៃការវិភាគរបស់ខ្លួនដើម្បីឲ្យមេធាវីការពារក្ដីអាចធានាថាគ្រប់កិច្ចស៊ើបសួរដែលចាំបាច់ទាំងអស់ត្រូវបានបំពេញ ក្នុងការកំណត់អំពីភស្តុតាងដោះបន្ទុកដ៏មានសក្ដានុពល និង

ង. បង្គាប់ឲ្យ កសចស ផ្ដល់នូវបញ្ជីភស្តុតាងដោះបន្ទុក ដែលមាននៅក្នុង SMD ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៩

AVOCAT ATTORNEY AT LAW KINGDOM OF

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**